**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MOSALVY

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ : ១៧ សកបយ.

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០០២

# ស ា រ ា ច រ
## ស្តីពី
## ការដោះស្រាយវិវាទការងារ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបលោក លោកស្រីជាម្ចាស់ និងជានាយកសហគ្រាស គ្រឹះស្ថាន បងប្អូនកម្មករនិយោជិត និងអង្គការវិជ្ជាជីវៈនានា ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ ហើយមានទីតាំងធ្វើការងារនៅក្នុងរាជធានីភ្នំពេញបានជ្រាបថា ចាប់ពីពេលនេះតទៅនៅពេលមានវិវាទការងារកើតឡើងទាំងវិវាទការងាររួម ទាំងវិវាទបុគ្គល សូមអស់លោក លោកស្រីជូនដំណឹងឬដាក់ពាក្យបណ្តឹងទៅប៉ុស្តិ៍អធិការកិច្ចការងារនៅតាមខ័ណ្ឌដែលសហគ្រាសគ្រឹះស្ថានរបស់ខ្លួនស្ថិតនៅ ដើម្បីមន្ត្រីអធិការកិច្ចការងារនៅតាមប៉ុស្តិ៍ពិនិត្យ និងដោះស្រាយវិវាទការងារនោះបានឆាប់រហ័សជាង ។ ប៉ុស្តិ៍អធិការកិច្ចការងារទាំងនោះមានអាសយដ្ឋាន ដូចមាននៅក្នុងឧបសម្ព័ន្ធជូនភ្ជាប់ជាមួយ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រីជាម្ចាស់ និងជានាយកសហគ្រាស គ្រឹះស្ថាន បងប្អូនកម្មករនិយោជិត អង្គការវិជ្ជាជីវៈដែលស្ថិតនៅក្នុងខ័ណ្ឌសីមានៃរាជធានីភ្នំពេញ ច្បាស់ជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារខាងលើបានល្អប្រសើរពុំខាន ។

**រដ្ឋមន្ត្រី**
**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**អ៊ិត សំហេង**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
-សាលាក្រុងភ្នំពេញ
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច

ឧបសម្ព័ន្ធនៃសារាចរ

លេខ: ១៧ សកបយ. ចុះថ្ងៃទី០៥ ខែ កក្កដា ឆ្នាំ២០០២

ស្តីពីការដោះស្រាយវិវាទការងារ

## អាសយដ្ឋានប៉ុស្តិ៍អធិការកិច្ចការងារតាមខណ្ឌនៃរាជធានីភ្នំពេញ

១-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌមានជ័យ: នៅសាលាខណ្ឌមានជ័យ ផ្ទះលេខ ០៣ , ផ្លូវលេខ៣៦១, ភូមិព្រែក សង្កាត់ច្បារអំពៅទី១ លេខទូរស័ព្ទទំនាក់ទំនង ០១៦. ៨៨៥ ០០៥- ០១២ .៨៤៥ ២១៤ ។

២-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌចំការមន: នៅសាលាខណ្ឌចំការមន ផ្ទះលេខ១៦៩, ផ្លូវម៉ៅសេទុង, ភូមិ១ សង្កាត់បឹងកេងកងទី៣ លេខទូរស័ព្ទទំនាក់ទំនង ០១២. ៨៧២ ៥៦៥- ០១២. ៨៣៦ ១០៥ ។

៣-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌដង្កោ: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១២. ៩៤៥ ០៥៥- ០១១. ៨៧៣ ៧៨៧ ។

៤-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌឫស្សីកែវ: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១៦. ៨៨០ ២០៩- ០១១. ៩៧៣ ២៥៥ ។

៥-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌទួលគោក: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១២. ៩២០ ៤៤៩- ០១១. ៨៧២ ៩៧២ ។

៦-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌដូនពេញ: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១២. ៨៦៨ ៣៧៧ ។

៧-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌ៧ មករា: នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១៦. ៨៩៧ ៩៣៥ ។